មន្ទីរសារការីភ្នំពេញ
PHNOM PENH NOTARY PUBLIC

# ដំណឹងជ្រើសរើសកម្មសិក្សាការី

**មន្ទីរសារការីភ្នំពេញ** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ របស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីបំពេញបេសកកម្មមួយចំនួនរបស់សារការី ក្នុងការធានាភាពស្របច្បាប់ និងសុវត្ថិភាពតាមផ្លូវច្បាប់ដល់រាល់លិខិតគតិយុត្ត និងកិច្ចសន្យានានារបស់អតិថិជន។

បច្ចុប្បន្ន **មន្ទីរសារការីភ្នំពេញ** ត្រូវការជ្រើសរើសកម្មសិក្សាការីចំនួន ០២ រូប ដែលមានបំណងទទួលបានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យសារការី នៅមន្ទីរសារការីភ្នំពេញ។

**អំពីភារកិច្ច ៖**

- ធ្វើការស្រាវជ្រាវផ្នែកច្បាប់
- តាក់តែងឯកសារ ឬលិខិតឆ្លើយឆ្លងជាមួយនឹងស្ថាប័នរដ្ឋ និងអតិថិជន
- បកប្រែឯកសារផ្នែកច្បាប់ ឬឯកសារពាក់ព័ន្ធដទៃផ្សេងទៀត ដូចជាច្បាប់ កិច្ចសន្យា ឬលក្ខន្តិកៈក្រុមហ៊ុន ជាអាទិ៍
- បំពេញការងារផ្សេងទៀតដែលមន្ទីរសារការីភ្នំពេញផ្ទុកផ្ដាក់ឱ្យ។

**អំពីកត្តាគុណវុឌ្ឍិ ៖**

- ត្រូវមានកំរិតវប្បធម៌បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ
- ចេះប្រើប្រាស់កុំព្យូទ័រ *(World & Excel)* និងប្រព័ន្ធអ៊ីនធើណែត
- ចេះភាសាអង់គ្លេស (ចេះភាសាបារាំងកាន់តែប្រសើរ)

ចំពោះបេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតបញ្ជាក់អំពីចំណាប់អារម្មណ៍របស់ខ្លួន មកមន្ទីរសារការីភ្នំពេញ ដែលមានអាសយដ្ឋានស្ថិតនៅអាគារកាណាឌីយ៉ាលេខ ៣១៥ (ជាន់ទី១២) ផ្លូវព្រះអង្គឌួង កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ តាមរយៈអ៊ីម៉ែល info@ppnp.com.kh **ឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ១៧ និង ០០ នាទី ។**

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងតាមរយៈទូរស័ព្ទលេខ៖ *០២៣ ៤៣១ ៧៨៩ ។*